00281843

E11

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# នៅចំពោះមុខការិយាល័យសហព្រះរាជអាជ្ញា

សំណុំរឿងក្ដីលេខ : 001/18-07-2007អ.វ.ត.ក/ក.ស.ច.ស

កាលបរិច្ឆេទរបស់ឯកសារ : ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៩

ភាគីអ្នកដាក់ : សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

ភាសាដើម : ភាសាអង់គ្លេស

ប្រភេទនៃឯកសារ : សាធារណៈ (ឯកសារដែលបានលុបចោលខ្លះ)

## សំណើសុំឲ្យមានកិច្ចស៊ើបអង្កេតបន្ថែមបន្ថែមរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

**ដាក់ជូនដោយ**

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យង់ ផានិត

លោកស្រី Silde STUDZINSKY

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

**ជំនួយការផ្នែកច្បាប់ :**

លោកស្រី Sibylle DISCHLER

**ជូនចំពោះ**

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Alex BATES

**ចម្លងជូន :**

អង្គជំនុំជម្រះសាលាដំបូង :

លោកចៅក្រម **និល ណុន** ប្រធាន

លោកស្រីចៅក្រម Silvia CARTWRIGHT

លោកចៅក្រម **យ៉ា សុខន**

លោកចៅក្រម ~~Jean-Marc LAVERGNE~~

លោកចៅក្រម ធួ មុនី

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 02 / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

ឯកសារដើមត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 09 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

00281844

E11

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោក Pierre Olivier SUR

**ជនជាប់ចោទ :**

លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច

**សហមេធាវីការពារក្តី :**

លោក ការ សាវុត្ថ

លោក Francois ROUX

E11

## ក. សាវតារអង្គហេតុ

១. ទោះបីជាពីមុនអ្នកប្រវត្តិសាស្ត្រមួយចំនួនបាននិយាយអំពីអាពាហ៍ពិពាហ៍រួមដែលត្រូវបានរៀបចំដោយខ្មែរក្រហមយ៉ាងណាក៏ដោយ[1] ក៏អង្គហេតុទាំងនោះមិនមែនជាផ្នែកនៃកិច្ចស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញាឡើយ និងមិនមានលក្ខណៈជាឧក្រិដ្ឋកម្មមួយឡើយ។ អង្គហេតុទាំងនេះត្រូវបានគេបំភ្លេចថាវាក៏ជាឧក្រិដ្ឋកម្មមួយដែរ។ សាក្សីក៏មិនត្រូវបានគេសួរអំពីអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះឡើយ។ ដូច្នេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលកំណត់ឱ្យមានកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស")[2] មិនបានបញ្ជាក់អំពីឧក្រិដ្ឋកម្មផ្លូវភេទ ឬអាពាហ៍ពិពាហ៍ដោយបង្ខំឡើយនៅក្នុងអង្គហេតុនៃសំណុំរឿងទេ។

២. ទោះបីជាយ៉ាងណាក៏ដោយ កិច្ចស៊ើបអង្កេតទាំងនោះបានរកឃើញនូវដំណើររឿងមួយចំនួននៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបង្ហាញឱ្យឃើញថា អាពាហ៍ពិពាហ៍រួមដែលត្រូវបានគេរៀបចំនោះ បានកើតមាននៅទូទាំងប្រទេស ក្រោមការដឹកនាំរបស់ខ្មែរក្រហម[3]។

៣. ភស្តុតាងនៅក្នុងសំណុំរឿងក៏បង្ហាញផងដែរថា យ៉ាងហោចណាស់ក៏មានអាពាហ៍ពិពាហ៍រួមមួយត្រូវបានគេរៀបចំធ្វើនៅ[បានលុបចោល] ដែលស្ថិតនៅក្រោមការត្រួតពិនិត្យពីជន

---

[1] Ben Kiernan, Cambodia: ការសម្លាប់រង្គាលនៅភូមិភាគបូព៌ា, Documentation Series: No. 1, មជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីសិទ្ធិមនុស្ស, Columbia University, Stockholm (1987), ទំព័រ៣៥។ Elisabeth Becker, នៅពេលសង្គ្រាមបានបញ្ចប់, New York (1986), ទំព័រ២៥៧។ Laura McGrew, ស្ត្រីកម្ពុជានៅឆ្នាំសូន្យ, 1999, http://advocacynet.org/resource/530, បានចូលអាននៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨។ McGrew បានធ្វើការសន្និដ្ឋានថា ស្ត្រីប្រមាណ ២០០.០០០នាក់ អាចត្រូវបានគេបង្ខំឱ្យរៀបការ។ ប្រសិនបើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងបរិបទប្រទេសកម្ពុជាមានអញ្ញាក្រឹតភាពផ្នែកយេនឌ័រ នោះចំនួនបុរសដូចគ្នានេះក៏អាចត្រូវបានគេគិតថាជាជនរងគ្រោះដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំនេះដែរ។

[2] សូមអានវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង។

[3] ឧទាហរណ៍: សោម ម៉ុន (Saom Mon), បទសម្ភាសន៍នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨, ឯកសារតុលាការ លេខ D28/11។ ដោយលោក ឌី ខាំបូលី ប្រវត្តិកម្ពុជាប្រជាធិបតេយ្យ, មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ (2007), ទំព័រ 32 et sequ., ដោយលោក Ian Harris, សាសនាព្រះពុទ្ធក្រោមរបប ប៉ុល ពត, DC-Cam, Phnom Penh (2007), ទំព័រ 19, 50, 53, 83, 127-129, 134, 226, 232។

ជាប់ចោទ។ សាក្សីម្នាក់បានរំឭកថា ប្រជាជនមកពីក្រុមរបស់គាត់ ពេទ្យ កម្មាភិបាល និងអ្នកផ្សេងទៀត ត្រូវបានគេកោះហៅមករៀបការ។ គូស្រកចំនួន២០-៣០ គូត្រូវបានគេរៀបការ នៅពេលតែមួយ[4]។

៤. យ៉ាងហោចណាស់ចាប់តាំងពីដើមឆ្នាំ១៩៧៧ អាពាហ៍ពិពាហ៍ទាំងនេះ ត្រូវបានរៀបចំ និងចាត់ចែងដោយ "អង្គការ" ហើយនៅក្នុងករណីជាច្រើន ការរួមភេទត្រូវបានគេហាមឃាត់[5]។ ពួកខ្មែរក្រហមបានលុបចោលទំនៀមទម្លាប់ និងពិធីជាប្រពៃណីរបស់ប្រជាជនកម្ពុជាក្នុងការរៀបអាពាហ៍ពិពាហ៍ ឧទាហរណ៍ ជាទូទៅក្រុមគ្រួសារមិនត្រូវបានគេអនុញ្ញាតឱ្យចូលរួមក្នុងពិធីរៀបការឡើយ ពីព្រោះពួកខ្មែរក្រហមចាត់ទុក "អង្គការ" គឺជាឪពុកម្ដាយរបស់មនុស្សគ្រប់គ្នា[6]។ ព្រះសង្ឃមិនអាចចំរើនពរដល់គូស្វាមីភរិយា ហើយពិធីរៀបការ ដែលជាធម្មតាមានតន្ត្រីប្រគុំ និងភ្ញៀវជាច្រើនចូលរួម ត្រូវបានគេហាមឃាត់មិនឱ្យមានទៀតឡើយ។
ជាធម្មតាគូស្វាមីភរិយាថ្មីថ្មោងមិនបានស្គាល់គ្នាពីមុនមកឡើយ ប៉ុន្តែពួកគេត្រូវតែប្រតិបត្តិតាមបទបញ្ជារបស់ "អង្គការ"។ បើពុំដូច្នេះទេ ពួកគេត្រូវបានគេចាត់ទុកថាជាខ្មាំងមិនគោរពតាមច្បាប់ដែលកំណត់ឡើងដោយ "អង្គការ" និងត្រូវទទួលទណ្ឌកម្ម[7]។ គូស្វាមីភរិយាថ្មីថ្មោងត្រូវបានគេចាត់ចែងឱ្យរួមដំណេកជាមួយគ្នានៅក្នុងខ្ទមតូចមួយរយៈពេលបីយប់ ដែលស្ថិតក្រោមការត្រួតពិនិត្យពីកងឈ្លប (ឈ្លប) ឬក៏ក្រោមការត្រួតពិនិត្យ

---

[4] [បានលុបចោល]

[5] ដោយលោកស្រី Peg LeVine, Love and Dread in Cambodia, Weddings and Births under the Khmer Rouge, ខែមេសា ឆ្នាំ២០០៨ មិនទាន់បានបោះពុម្ពនៅឡើយទេ។ អ្នកនិពន្ធបានសម្ភាសន៍មនុស្ស ១៩២នាក់ ដែលត្រូវបានគេរៀបការរួម ក្រោមរបបខ្មែរក្រហម។ អ្នកស្រីបានបញ្ជាក់ថា ប្រសិនបើមានការបង្គាប់បញ្ជាឱ្យរួមភេទ នោះភាគីបុរសជាអ្នកទទួល ការបង្គាប់បញ្ជានោះ។ បុរស ៧៦នាក់ ក្នុងចំណោម ៨៨នាក់ (ជាង ៨៦%) បានទទួលការបង្គាប់បញ្ជាឱ្យរួមភេទ។

[6] ដោយលោក Ratana C. Huy, Khmer Rouge Wedding, DC-Cam, ការស្វែងរកការពិត លេខ 25, ខែមករា ឆ្នាំ២០០២ ទំព័រ 26។

[7] សូមអានឯកសារយោងមុន ៦ ទំព័រ ២៨។

ពី“អង្គការ”។ ដោយសារមានការធ្លាក់ចុះនៃអត្រាកំណើតអាពាហ៍ពិពាហ៍ ទាំងនេះគឺជាមធ្យោបាយមួយនៃគោលនយោបាយប្រជាសាស្ត្រដើម្បីបង្កើតកូនបដិវត្តន៍ថ្មី[8]។

៥. ភស្តុតាងបង្ហាញច្បាស់ថា ព្រឹត្តការណ៍នៃអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះត្រូវបានរៀបចំដោយមេដឹកនាំជាន់ខ្ពស់ ហើយត្រូវបានគេអនុវត្តរាលដាលទូទាំងប្រទេស និងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិល។

## ខ. សេចក្តីសង្ខេបនត្ថិករណ៍

៦. ភស្តុតាងដែលបានផ្តល់ជូនបង្ហាញថា យ៉ាងហោចណាស់ការរៀបអាពាហ៍ពិពាហ៍មួយក្រុម ត្រូវបានគេរៀបចំ [បានលុបចោល] ដែលស្ថិតនៅក្រោមការត្រួតពិនិត្យពីជនជាប់ចោទ។ អាពាហ៍ពិពាហ៍រួមបែបនេះត្រូវបានគេចាត់ទុកថា ជាការរំលោភលើផ្លូវភេទ ការដាក់ជាទាសករ ការមានគភ៌ដោយបង្ខំ និងជាឧក្រិដ្ឋកម្មថ្មី នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីព្រោះជនដែលពាក់ព័ន្ធទាំងនោះស្ថិតនៅក្រោមកាលៈទេសៈបង្ខំ និងពុំមានការយល់ព្រមដោយពិតប្រាកដឡើយ។

៧. ឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងយេនឌ័រដ៏ធ្ងន់ធ្ងរទាំងនេះមានធាតុផ្សំយ៉ាងច្បាស់ និងអាចត្រូវបានចោទប្រកាន់បន្ថែមទៀត។ ទោះបីជាមានភស្តុតាងនៅក្នុងសំណុំរឿង ហើយអាពាហ៍ពិពាហ៍ដោយបង្ខំមាននៅគ្រប់កន្លែងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏ឧក្រិដ្ឋកម្មបែបនេះមិនត្រូវបានគេធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងមិនត្រូវបានគេបញ្ចូលក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ។

៨. ដើម្បីស្វែងរកការពិត កិច្ចស៊ើបអង្កេតបន្ថែមត្រូវបានស្នើឡើងដើម្បីសំដៅចោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មទាំងនេះ។ ដោយគិតទៅលើវិសាលភាពកំណត់នៃតម្រូវការកិច្ច

[8] សូមអានសៀវភៅរបស់លោក ឌី ខាំបូលី, ឯកសារយោងមុន ៣ ទំព័រ៣៥។

ស៊ើបអង្កេត យើងនៅតែអាចធ្វើការចោទប្រកាន់ជនជាប់ចោទបាន ទាំងក្នុងអំឡុងពេលដែលការជំនុំជម្រះក្ដីកំពុងប្រព្រឹត្តទៅ ដែលនឹងមិនត្រូវពន្យាពេលនោះទេ។

## គ. អាពាហ៍ពិពាហ៍ដោយបង្ខំក្រោមយុត្តិសាស្ត្រ និងច្បាប់អន្តរជាតិ

៩. នៅក្នុងសំណើសុំឱ្យមានកិច្ចស៊ើបអង្កេតបន្ថែម កិច្ចពិភាក្សាស្ដីអំពីភាពខុសគ្នារវាងអាពាហ៍ពិពាហ៍ ដែលរៀបចំតាមបែបប្រពៃណីនៅក្នុងបរិបទប្រទេសកម្ពុជាសម័យទំនើប និងអាពាហ៍ពិពាហ៍ដោយបង្ខំ ក្រោមការរៀបចំពីពួកខ្មែរក្រហមដែលជាឧក្រិដ្ឋកម្មថ្មីប្រឆាំងនឹងមនុស្សជាតិ នឹងត្រូវបានគេលុបចោល។
ទោះបីជាអាពាហ៍ពិពាហ៍ដែលត្រូវបានគេរៀបចំធ្វើឡើងដោយមិនមានការយល់ព្រមពីភាគីម្ខាង ឬភាគីទាំងសងខាង ជាការរំលោភបំពានមួយដ៏ធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏អាពាហ៍ពិពាហ៍បែបនេះមិនឈានដល់កំរិតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជាអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ ពីព្រោះអាពាហ៍ពិពាហ៍ ដែលត្រូវបានគេរៀបចំមិនមែនជា "ការវាយប្រហារ" ប្រឆាំងនឹងប្រជាជនស៊ីវិលទេ[9]។

១០. វាត្រូវបានគេទទួលស្គាល់ជាលក្ខណៈអន្តរជាតិថា ការយល់ព្រមទៅវិញទៅមករវាងភាគីទាំងសងខាង គឺជាកត្តាចាំបាច់ដំបូងមុននឹងមានការប្រារព្ធពិធីរៀបការ[10]។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានឱ្យនិយមន័យអាពាហ៍ពិពាហ៍*ដោយបង្ខំ*ថា ជាអាពាហ៍ពិពាហ៍ "ខ្វះការយល់ព្រមដ៏ពិតប្រាកដ និងដោយសេរី យ៉ាងហោចណាស់ពីសំណាក់ភាគីម្ខាងក្នុងចំណោមភាគីទាំងនោះ"[11]។ នៅក្នុងទម្រង់ដ៏ធ្ងន់ធ្ងរបំផុត អាពាហ៍ពិពាហ៍ដោយបង្ខំ

---

[9] Michael P. Scharf and Suzanne Mattler, អាពាហ៍ពិពាហ៍ដោយបង្ខំ: Exploring the Viability of the Special Court for Sierra Leone's New Crime Against Humanity, ឯកសារស្រាវជ្រាវពីករណីក្នុងការសិក្សាអំពីច្បាប់ (2005), http:ssrn.com/abstract=824291, ចូលអានចុងក្រោយនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ១២។

[10] មាត្រា ១៦(២) នៃសេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស, មាត្រា ២៣(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ១(១) នៃអនុសញ្ញា ស្ដីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍។

[11] របាយការណ៍របស់អគ្គលេខាធិការ, ការសិក្សាដ៏លំអិតទៅលើទម្រង់ទាំងអស់នៃហិង្សាប្រឆាំងនឹងស្ត្រី A/61/122/Add.1. 2006, កថាខណ្ឌ ១២២។

បែបនេះអាចពាក់ព័ន្ធទៅនឹងឥរិយាបថគំរាមកំហែង ការចាប់ពង្រត់ ការបង្ខាំង ការរំលោភបំពានលើរាងកាយ ការរំលោភលើផ្លូវភេទ និងអំពើឃាតកម្មនៅក្នុងករណីខ្លះទៀត[12]។

១១. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការពិសេសសម្រាប់ Sierra Leone បានរកឃើញថា ភស្តុតាងនៃករណីអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវគេបញ្ចូលទាំងស្រុងទៅក្នុងប្រភេទឧក្រិដ្ឋកម្មទាសភាពផ្លូវភេទ ហើយថាមិនមានភាពចន្លោះប្រហោងនៅក្នុងច្បាប់ដែលកំណត់ថា ឧក្រិដ្ឋកម្មដោយឡែកនៃអាពាហ៍ពិពាហ៍ដោយបង្ខំគឺជា "អំពើអមនុស្សធម៌ផ្សេងទៀត" ឡើយ[13]។ គួរឲ្យកត់សំគាល់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា តាមបែបតក្កវិជ្ជាតម្រូវឲ្យបកស្រាយបទល្មើសនៃ "អំពីអមនុស្សធម៌ផ្សេងទៀត" ថាជាការសំដៅតែចំពោះអំពើដែលមានលក្ខណៈមិនរួមភេទប៉ុណ្ណោះ ពីព្រោះលក្ខន្តិកៈតុលាការមានបញ្ចូលប្រភេទទាំងស្រុងនៃឧក្រិដ្ឋកម្មផ្លូវភេទរួចហើយ[14]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ភស្តុតាងនោះមិនបានបង្ហាញ "សូម្បីតែឧទាហរណ៍មួយដែលស្ត្រីឬកុមារីម្នាក់ត្រូវបានបង្ខំឲ្យរៀបការដោយក្លែងក្លាយ នៅក្នុងកាលៈទេសៈដែលមិនមានកម្រិតជាទាសភាពផ្លូវភេទឡើយ"[15]។ លើសពីនេះទៀត ប្រសិនបើមានភស្តុតាងបែបនេះមែន វាក៏មិនមានកម្រិតជា "អំពើអមនុស្សធម៌" ដែរ ពីព្រោះវាមិនមានស្ថានទម្ងន់ស្រដៀងទៅនឹងឧក្រិដ្ឋកម្មដែលបានរៀបរាប់ប្រឆាំងនឹងមនុស្សជាតិ ដែលតម្រូវឲ្យមានការប្រព្រឹត្តនោះមានលក្ខណៈជា "អំពើអមនុស្សធម៌" ឡើយ។

[12] សូមអានឯកសារយោងមុន ១១ កថាខណ្ឌ ១២២។

[13] ព្រះរាជអាជ្ញា ទល់និង *Alex Tamba Brima et al.*, (SCSL-04-16-T), អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ សាលក្រម កថាខណ្ឌ ៧១៣។

[14] សូមអានឯកសារយោងមុន ១៣ កថាខណ្ឌ ៦៩៧។

[15] សូមអានឯកសារយោងមុន ១៣ កថាខណ្ឌ ៧១០។

១២. នៅចំពោះមុខអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ Sierra Leone អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានគេទទួលស្គាល់ជាលើកដំបូង ថាជាឧក្រិដ្ឋកម្មថ្មីមួយប្រឆាំងនឹងមនុស្សជាតិនៅក្នុងតុលាការដែលមានលក្ខណៈអន្តរជាតិ[16]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានលើកផ្នែកសំអាងហេតុដ៏គួរឱ្យកត់សំគាល់ចំនួនបី។ ទីមួយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានយល់ឃើញថា ការដាក់បញ្ចូលទាំងស្រុងនៃឧក្រិដ្ឋកម្មផ្លូវភេទនៅក្នុងមាត្រា ២(ឆ) នៃលក្ខន្តិកៈនោះ មិនបានទាត់ចោលឡើយនូវលទ្ធភាពក្នុងការចោទប្រកាន់ "អំពើអមនុស្សធម៌ផ្សេងទៀត" ដែលមានធាតុផ្សំទាក់ទិននឹងយេនឌ័រ ឬផ្លូវភេទ ក្រោមមាត្រា ២(ឈ)[17]។ ទីពីរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញថា អាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានគេបញ្ចូលនៅក្នុងឧក្រិដ្ឋកម្ម នៃទាសភាពផ្លូវភេទឡើយ[18]។ ទោះបីជាអាពាហ៍ពិពាហ៍ដោយបង្ខំ ដូចជាទាសភាពផ្លូវភេទដែរពាក់ព័ន្ធទៅនឹងការរួមភេទដោយមិនមានការយល់ព្រម និងការដកហូតសេរីភាពយ៉ាងណាក៏ដោយ វាក៏មានលក្ខណៈខុសគ្នាដែរ ដូចជា "ការចូលរួមជាសម្ពន្ធប្តីប្រពន្ធដោយបង្ខំ" ដែលមិនដូចទាសករផ្លូវភេទទេ ពាក់ព័ន្ធទៅនឹងភាពផ្តាច់មុខរវាង "ស្វាមី" និង "ភរិយា"[19]។ សំអាងហេតុចុងក្រោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញថាករណីជាច្រើននៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងជម្លោះក្នុងប្រទេស Sierra Leone មានស្ថានទម្ងន់ស្រដៀងទៅនឹងឧក្រិដ្ឋកម្មផ្សេងទៀតប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់តុលាការ[20]។

---

[16] ព្រះរាជអាជ្ញា ទល់និង *Alex Tamba Brima et al.*, (SCSL-04-16-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ សាលដីកា កថាខណ្ឌ ១៧៥-២០២។

[17] សូមអានឯកសារយោងមុន ១៦ កថាខណ្ឌ ១៨៦។

[18] សូមអានឯកសារយោងមុន ១៦ កថាខណ្ឌ ១៩៥។

[19] សូមអានឯកសារយោងមុន ១៦ កថាខណ្ឌ ១៩៥។

[20] សូមអានឯកសារយោងមុន ១៦ កថាខណ្ឌ ២០០។

១៣. នៅក្នុងបរិបទប្រទេស Rwanda បញ្ហានេះត្រូវបានគេពិភាក្សា និងបានស្នើបញ្ចូល "អាពាហ៍ពិពាហ៍ដោយបង្ខំ" ជាឧក្រិដ្ឋកម្មជាក់លាក់ ក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[21]។

## ឃ. អាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងបរិបទប្រទេសកម្ពុជា

### I. អាពាហ៍ពិពាហ៍ដោយបង្ខំជាការវាយប្រហារជាលក្ខណៈប្រព័ន្ធ ឬរាលដាល សំដៅប្រឆាំងនឹងប្រជាជនស៊ីវិល

១៤. អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេរៀបចំធ្វើឡើងទូទាំងប្រទេស ហើយចាប់ពីដើមឆ្នាំ១៩៧៧ វាមានលក្ខណៈជាប្រព័ន្ធ និងរាលដាលទូទាំងប្រទេស។ ប្រជាពលរដ្ឋដែលមិនទាន់រៀបការ ហើយមានអាយុលើសពី១៨ឆ្នាំឡើងទៅ គឺជាមុខសញ្ញានៃការវាយប្រហារនោះ។ ក្នុងចំណោមក្រុមគោលដៅទាំងនោះ ភាគច្រើនជាកម្មាភិបាល និងយោធា ហើយវាមិនទាន់ដាច់ស្រេចនៅឡើយថាតើអ្នកទាំងនោះស្ថិតនៅក្រោមពាក្យថាប្រជាជនស៊ីវិលដែរ ឬយ៉ាងណា។

១៥. ការបាត់រូបរាងជាបន្តបន្ទាប់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នូវទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ នាំឲ្យការសង្កត់ធ្ងន់ថា ជនស៊ីវិលថាជាក្រុមគោលដៅតែមួយគត់ប៉ុណ្ណោះ បានធ្លាក់ចុះខ្សោយ។
ប្រភេទមនុស្សដែលទទួលបាននូវការការពារត្រូវបានគេពង្រីកបន្ថែមរហូតដល់មានការការពារនូវតម្លៃជាមូលដ្ឋាននៃសេចក្តីថ្លៃថ្នូររបស់មនុស្សដោយមិនគិតអំពីឋានៈស្របច្បាប់របស់បុគ្គល ដែលទទួលបានសិទ្ធិការពារបែបនេះឡើយ។ មិនមានហេតុផលដែលគួរយកមកពិចារណាចំពោះការបដិសេធមិនអនុវត្តសញ្ញាណ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅលើអំពើអមនុស្សធម៌ និងឃោរឃៅ ដែលត្រូវបានប្រព្រឹត្តឡើងជាទ្រង់ទ្រាយធំដោយ

---

[21] Monika Satya Kalra, អាពាហ៍ពិពាហ៍ដោយបង្ខំៈ អាថ៌កំបាំងរបស់ប្រទេសរ្វ៉ាន់ដាត្រូវបានលាតត្រដាង (2001) 7 U.C. Davis Journal of International Law and Policy 197 (2001).

រដ្ឋាភិបាលប្រឆាំងនឹងសេចក្តីថ្លៃថ្នូរជាមនុស្សរបស់កងទ័ពនៃរដ្ឋាភិបាលទាំងនោះបានឡើយ[22]។

លើសពីនេះទៀត ប្រសិនបើមនុស្សដែលជាប់ពាក់ព័ន្ធទាំងនោះមិនត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិទេ នោះការរំលោភបំពានដ៏ធ្ងន់ធ្ងរមកលើពួកគេស្ថិតនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

១៦. ដូច្នេះ បុគ្គលិកយោធា និងកម្មាភិបាលទាំងឡាយដែលត្រូវបានបង្ខំឱ្យរៀបការ ស្ថិតនៅក្រោមប្រភេទជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

## II. អាពាហ៍ពិពាហ៍ដោយបង្ខំ និងចេតនារើសអើង

១៧. យោងតាមមាត្រា៥ នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ[23] ("ច្បាប់ អ.វ.ត.ក") កត្តាដំបូងនៃចេតនារើសអើងមិនត្រូវបានកំណត់ត្រឹមតែជាឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ប៉ុណ្ណោះទេ ប៉ុន្តែរាប់បញ្ចូលទាំងសមាសធាតុបន្ថែមចំពោះឧក្រិដ្ឋកម្មទាំងអស់ ដែលបានរៀបរាប់។ លើសពីនេះទៀត អនុលោមតាមច្បាប់ អ.វ.ត.ក ការវាយប្រហារ ប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាដ៏ដោយ ប្រាកដជាផ្អែកលើ "មូលហេតុជនជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬក៏សាសនាជាក់ជាមិនខាន"។

ផ្ទុយទៅវិញ មាត្រា១២នៃកិច្ចព្រមព្រៀង[24] រវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា យោងទៅលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ១៩៩៨ នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ("ICC") ជាទូទៅមិនចាំបាច់តម្រូវឱ្យមានមូលហេតុនៃការរើសអើងសម្រាប់ការវាយប្រហារណា

---

[22] Antonio Cassese, ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ, Oxford (2008), ទំព័រ ១២២។

[23] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើវិសោធនកម្ម និងប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដោយមានបញ្ចូលនូវការធ្វើវិសោធនកម្មដូចដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៤។

[24] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះខែមិថុនា ឆ្នាំ២០០៣ ចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។

មួយឡើយ។ លើសពីនេះទៀត ចំពោះឧក្រិដ្ឋកម្ម "ធ្វើទុក្ខបុកម្នេញ" គេបានរាប់បញ្ចូលនូវកត្តា "យេនឌ័រ" និង "វប្បធម៌" នៅក្នុងនោះ។

១៨. កង្វះភាពស្របគ្នារវាងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក បង្កើតឱ្យមានចម្ងល់ អំពីទំនាក់ទំនងរវាងឯកសារទាំងពីរ ដែលឯកសារទាំងពីរនេះត្រូវបានយកមកអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុលោមតាមមាត្រា៣១ នៃកិច្ចព្រមព្រៀង កិច្ចព្រមព្រៀងនេះត្រូវបានយកមកប្រើជា*ច្បាប់*បន្ទាប់ពីការផ្តល់សច្ចាប័នរួចហើយ[25]។ ប្រការនេះបង្ហាញឱ្យឃើញថា កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពពេញទីនៅក្នុងប្រទេសកម្ពុជា ហើយក៏បង្ហាញឱ្យឃើញថា បទប្បញ្ញត្តិដែលបានចែងនោះនៅជាធរមានពេញទី[26]។ ស្របតាមអនុសញ្ញាទីក្រុងវីយែនស្តីអំពីច្បាប់សន្ធិសញ្ញា[27] កិច្ចព្រមព្រៀងនោះមានអធិកភាពទៅលើបទដ្ឋានដែលមានលក្ខណៈផ្ទុយគ្នា និងមិនស៊ីគ្នាជាមួយច្បាប់ អ.វ.ត.ក[28]។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកលើឧប្បត្តិដ្ឋានពីដំបូងនៃពង្រាងច្បាប់ អ.វ.ត.ក ពី ឆ្នាំ២០០១ ទំនងជាបង្ហាញច្បាស់ថា ភាពខុសគ្នារវាងច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺបណ្តាលមកពីការខ្វះការយកចិត្តទុកដាក់ឱ្យបានម៉ត់ចត់[29]។ ដូច្នេះ ទាក់ទិនទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស

---

[25] បញ្ហានេះបានកើតឡើងនៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤។ សូមអានព័ត៌មានប្រចាំថ្ងៃរបស់អង្គការសហប្រជាជាតិ ចេញផ្សាយ DH/4283 ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៤, http://www.un.org/news/dh/pdf/english/03122004.pdf , បានចូលអាននៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩។

[26] សូមអាន Cesare P.R. Romano/André Nollkaemper/Jann K. Kleffner, តុលាការឧក្រិដ្ឋកម្មដែលមានលក្ខណៈអន្តរជាតិ – នៅSierra Leone, ទីម័រខាងកើត, កូសូវ៉ូ និងកម្ពុជា, Oxford (2004), ទំព័រ ២១០។

[27] សូមអាន មាត្រា ២(២) នៃកិច្ចព្រមព្រៀង។

[28] សូមអានឯកសារយោងមុន ២៦, ផងដែរសូមអាន Susanne Dyrchs, Das hybride Khmer Rouge-Tribunal – Entstehung, Entwicklung und rechtliche Grundlagen, Frankfurt am Main (2008), ទំព័រ ១២០។

[29] ពង្រាងដើមនៃច្បាប់ គឺជាច្បាប់មួយដែលអង្គការសហប្រជាជាតិមិនបានយល់ស្របទៅលើច្បាប់នោះឡើយ។ វាផ្អែកទៅលើការចរចាមុនពេលមានការអនុម័តលក្ខន្តិកៈទីក្រុងរ៉ូម ដែលប្រទេសកម្ពុជាគឺជាភាគីមួយ ហើយវាបានបញ្ចូលនូវការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចនៅក្នុងលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា។ គោលបំណងនៃកិច្ចព្រមព្រៀងនោះ គឺដើម្បីធ្វើវិសោធនកម្មច្បាប់ អ.វ.ត.ក ដែលមានស្រាប់ ចុះកាលបរិច្ឆេទចាប់ពីឆ្នាំ២០០១។ ប៉ុន្តែការផ្លាស់ប្តូរដែលបានដាក់ស្នើដោយកិច្ចព្រមព្រៀងនោះ មិនទាន់ត្រូវបានធ្វើវិសោធនកម្មនៅ

ជាតិ ការកំណត់អត្ថន័យដ៏សំខាន់ដើម្បីយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក គឺជាការកំណត់អត្ថន័យតាមលក្ខន្តិកៈទីក្រុងរ៉ូម ដូចដែលបានយោងនៅក្នុងមាត្រា៩ នៃកិច្ចព្រមព្រៀង។

១៩. យោងតាមលក្ខន្តិកៈទីក្រុងរ៉ូម ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលតាមរយៈការរៀបចំអាពាហ៍ពិពាហ៍រួម មិនចាំបាច់តម្រូវឱ្យមានមូលហេតុក្នុងការរើសអើងណាមួយឡើយ។ ដោយត្រូវបានដាក់បញ្ចូលក្នុងឧក្រិដ្ឋកម្ម "ធ្វើទុក្ខបុកម្នេញ" អំពើនោះត្រូវបានផ្អែកទៅលើមូលហេតុ "យេនឌ័រ"។

## ខ. ចរិតលក្ខណៈផ្នែកច្បាប់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងបរិបទប្រទេសកម្ពុជា

### I. អាពាហ៍ពិពាហ៍ដោយបង្ខំជាការរំលោភផ្លូវភេទ និងជាការដាក់មនុស្សជាទាសករក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មាត្រា៥ នៃច្បាប់ អ.វ.ត.ក និងការមានគភ៌ដោយបង្ខំ ក្រោមមាត្រា៩ នៃកិច្ចព្រមព្រៀង។

#### *១. អាពាហ៍ពិពាហ៍ដោយបង្ខំជាការរំលោភផ្លូវភេទ ក្រោមមាត្រា៥ នៃច្បាប់ អ.វ.ត.ក។*

២០. បន្ទាប់ពីការបញ្ចប់ពិធីរៀបអាពាហ៍ពិពាហ៍ ស្វាមី និងភរិយាតែងត្រូវបានគេតម្រូវឱ្យរួមដំណេកជាមួយគ្នាមួយយប់ ឬយ៉ាងយូរបំផុតមួយសប្តាហ៍ មុនពេលពួកគេត្រូវបានបំបែកទៅតាមអង្គភាពធ្វើការវិញ។ ក្នុងករណីខ្លះ ការរួមដំណេកនេះត្រូវបានត្រួតពិនិត្យដោយកងឈ្លប (ឈ្លប) ឬក៏ត្រូវបានត្រួតពិនិត្យដោយ "អង្គការ"[30]។ បន្ទាប់មក ស្វាមី និងភរិយា

---

ឡើយទេ។ សូមអានសៀវភៅនិពន្ធដោយ Craig Etcheson, A "Fair and Public Trial": A Political History of the Extraordinary Chambers, Justice Initiative (2006), http://www.justiceinitiative.org/db/resource2?res_id=103182, បានចូលអាននៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩។

[30] សូមអានសៀវភៅរបស់អ្នកស្រី ម៉ម កល្យាណី, កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩): Women as Tools for Social Change, New Haven, (2000), ទំព័រ ៧០។

ទាំងនោះត្រូវបានគេអនុញ្ញាតឱ្យជួបគ្នាមួយដងជារៀងរាល់ប្រាំពីរថ្ងៃទៅដប់ថ្ងៃដើម្បីរួមដំណេកជាមួយគ្នាមួយយប់[31]។ នៅគ្រប់ករណីទាំងអស់ មិនត្រឹមតែ "អង្គការ" ប៉ុណ្ណោះទេដែលរំពឹង[32] ថាស្វាមីភរិយាទាំងនោះនឹងបានរួមភេទជាមួយគ្នា ប៉ុន្តែថ្នាក់លើក៏បានបញ្ជាចំៗផងដែរឱ្យស្វាមីភរិយាទាំងនោះរួមភេទជាមួយគ្នា។ ការស្រាវជ្រាវបង្ហាញឱ្យឃើញថាបុរសចំនួន៧៦នាក់ ក្នុងចំណោម៨៨នាក់ ត្រូវបានគេបញ្ជាឱ្យរួមភេទត្រង់ៗតែម្តងជាមួយភរិយាដែលទើបត្រូវបានគេរៀបការឱ្យ[33]។ នេះមានន័យថា ចំនួនបុរសជាច្រើនគួរឱ្យកត់សំគាល់ត្រូវបានគេបង្ខំឱ្យរួមភេទជាមួយស្ត្រី ប្រឆាំងនឹងឆន្ទៈរបស់ស្ត្រីនោះ ហើយក៏ប្រឆាំងនឹងឆន្ទៈខ្លួនឯងផងដែរ។ តាមពិត ការដាក់បញ្ចូលអង្គជាតិទៅក្នុងប្រដាប់ភេទស្ត្រីនៅពេលរួមភេទដោយបង្ខំ ជាការរំលោភផ្លូវភេទ មិនត្រឹមតែប្រឆាំងនឹងស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប្រឆាំងទៅនឹងភាគីបុរសផងដែរ។

ទោះបីជាមិនមានការបញ្ជាដោយផ្ទាល់ក៏ដោយ ក៏គូស្វាមីភរិយាថ្មីថ្មោងយល់ថា ការរួមភេទគឺជាផ្នែកមួយដ៏សំខាន់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយថាពួកគេត្រូវបានគេតម្រូវឱ្យរួមភេទដើម្បីបង្កើតកូន។

២១. ក្នុងចង្កោមដែលមានលក្ខណៈពិសេសតែមួយគត់នេះ ការរួមភេទដែលត្រូវបានបញ្ជា ដោយផ្ទាល់ និងត្រូវបានរំពឹងទុកដោយប្រយោល ដែលជាផ្នែកមួយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គួរត្រូវបានចោទប្រកាន់ថា ជាការចាប់រំលោភ ដូចជាបទចោទដោយឡែកមួយក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

## *២. ការដាក់ជាទាសករ ក្រោមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក*

---

[31] សូមអានសៀវភៅរបស់លោក ឌី ខាំបូលី ដូចឯកសារយោងមុន ៣ ទំព័រ ៣៤, ដូចឯកសារយោងមុន ៣០ ទំព័រ ៥៦។

[32] នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ គូស្វាមីភរិយាត្រូវតែសន្យាថា ពួកគេនឹងបង្កើតកូនមួយក្នុងរយៈពេលមួយឆ្នាំ។ សូមអានបទសម្ភាសន៍លោក ហ្សេង ផេង នៅក្នុងសៀវភៅរបស់លោក ឌី ខាំបូលី ដូចឯកសារយោងមុន ៣ ទំព័រ ៣៤។

[33] សូមអានឯកសារយោងមុន ៥។

២២. ការដាក់ជាទាសករ គឺជាឧក្រិដ្ឋកម្មមួយប្រឆាំងនឹងមនុស្សជាតិ តម្រូវថា "បុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋបានប្រើប្រាស់អំណាចណាមួយ ឬអំណាចទាំងអស់ដែលមានជាប់នឹងសិទ្ធិកម្មសិទ្ធិទៅលើជនម្នាក់ ឬច្រើន ដូចជាតាមរយៈការទិញ លក់ ឲ្យខ្ចី ឬដោះដូរជនម្នាក់នោះ ឬច្រើន ឬតាមរយៈការដាក់ការដកហូតស្រដៀងគ្នាមួយនូវសេរីភាព"[34]។

២៣. ប្ដីប្រពន្ធត្រូវបានហៅឲ្យមកប្រជុំ រៀបការ និងបន្ទាប់មកត្រូវបានចាត់តាំងឲ្យគេងជាមួយគ្នា និងជួបសួរសុខទុក្ខរបៀបប្ដីប្រពន្ធ នៅពេលក្រោយ។ មនុស្សត្រូវបានគ្រប់គ្រង និងបញ្ជាអំពីរបៀប ទីកន្លែង និងពេលវេលា ដែលពួកគេត្រូវរស់នៅជីវិតជាប្ដីប្រពន្ធ ក្នុងនាមជាប្ដីប្រពន្ធដែលបានរៀបការជាមួយគ្នា។ ការអនុវត្តន៍បែបនេះ គួរត្រូវបានចាត់ទុកជា ការដាក់ជាទាសករ ព្រោះវាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

៣. *ការមានផ្ទៃពោះដោយបង្ខំក្រោមកិច្ចព្រមព្រៀង (ឬការជំនួសដោយ ពាក្យថា"អំពើអមនុស្សធម៌ផ្សេងៗ" ឬពាក្យថា "ដូចជា" ក្រោមច្បាប់ អ.វ.ត.ក)*

២៤. ឧក្រិដ្ឋកម្មស្ដីពីការមានផ្ទៃពោះដោយបង្ខំ គឺមិនត្រូវបានរាប់បញ្ចូលក្នុងច្បាប់ អ.វ.ត.ក ឡើយ ក៏ប៉ុន្តែមាននៅក្នុងកិច្ចព្រមព្រៀង ដោយយោងតាមច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ដែលគេបានរាប់បញ្ចូលការមានផ្ទៃពោះដោយបង្ខំ ជាទម្រង់ជាក់លាក់មួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[35]។

---

[34] ធាតុផ្សំនៃឧក្រិដ្ឋកម្មក្រោមច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧ (១) (គ) កថាខណ្ឌទី១។ កត្តានានាដែលចង្អុលបង្ហាញអំពីអត្ថិភាពនៃការដាក់មនុស្សឲ្យធ្វើជាទាសករ រួមមាន "ការគ្រប់គ្រងការផ្លាស់ទីរបស់មនុស្ស ការគ្រប់គ្រងបរិស្ថានផ្លូវកាយ ការគ្រប់គ្រងផ្លូវចិត្ត ការចាត់វិធានការណ៍ទប់ស្កាត់ ឬហាមឃាត់ការរត់គេចខ្លួន ការគម្រាមដោយកម្លាំងដោយការចាប់បង្ខំ ការចាប់ដាក់គុក ការអះអាងពីសិទ្ធិផ្ដាច់មុខ ការដាក់ឲ្យស្ថិតនៅក្រោមការធ្វើបាប និងរំលោភបំពានការគ្រប់គ្រងជីវភាពផ្លូវភេទ (...) ដីកាសន្និដ្ឋានស្ពាន របស់ការិយាល័យសហព្រះរាជអាជ្ញា ឯកសារតុលាការលេខ D៩៦ កថាខណ្ឌ១៩៥។

[35] មាត្រា៧ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ - លក្ខន្តិកៈបានចែងពីគោលបំណងនៃលក្ខន្តិកៈនេះ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" មានន័យថាជាអំពើណាមួយក្នុងអំពើខាងក្រោម ពេលត្រូវបានប្រព្រឹត្តជាផ្នែកមួយ នៃការវាយប្រហាររីករាលដាល ឬជាប្រព័ន្ធ សំដៅប្រឆាំងនឹងពលរដ្ឋស៊ីវិលណាមួយ ដោយបានដឹងអំពីការវាយប្រហារ៖ [...]

២៥. ដូចបានគូសបញ្ជាក់ខាងលើ[36]កិច្ចព្រមព្រៀងបានរាប់បញ្ចូលឧក្រិដ្ឋកម្ម "ការមានគ៌ភដោយបង្ខំ"ថាអាចយកមកអនុវត្តបានដោយផ្ទាល់ និងជាក់ស្តែង។ ឬនិយាយម៉្យាងទៀតថាឧក្រិដ្ឋកម្មអំពីការមានគ៌ភដោយបង្ខំ ស្ថិតក្រោមពាក្យថា "ដូចជា" ឬ ពាក្យថា "អំពើអមនុស្សធម៌ផ្សេងៗ" នៃមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដោយសារបញ្ហាប្រធានបទនៃការមានគ៌ភដោយបង្ខំនេះត្រូវបានទទួលស្គាល់ ថាជាឧក្រិដ្ឋកម្មក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ លើសពីនេះទៀតសោតបញ្ជីឧក្រិដ្ឋកម្មក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក នៅមិនទាន់លម្អិត[37] និងត្រូវតែបកស្រាយដោយយកកិច្ចព្រមព្រៀងមកធ្វើការពិចារណា។

២៦. អនុលោមតាមមាត្រា ៧ (១) (ឆ) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ការមានគ៌ភដោយបង្ខំ ត្រូវបានកំណត់និយមន័យថាជា "ការបង្ខាំងដោយខុសច្បាប់នូវស្ត្រីដែលត្រូវបានធ្វើឱ្យមានគ៌ភដោយបង្ខំដោយមានចេតនាចង់ឱ្យមានការប៉ះពាល់ដល់សមាសភាពជាតិពន្ធនៃពលរដ្ឋណាមួយ ឬ[38]ការអនុវត្តន៍ការបំពានដ៏ធ្ងន់ធ្ងរដទៃទៀតលើច្បាប់អន្តរជាតិ"[39]។

២៧. ដោយគិតដល់ចេតនាខ្មែរក្រហមក្នុងការបង្កើតសង្គមមួយថ្មី គោលបំណងមួយក្នុងចំណោមគោលបំណងចម្បងៗ នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការកើតមានផ្ទួនៗ នៃការរួមភេទដោយបង្ខំ គឺខ្មែរក្រហមមានចេតនាចង់ឱ្យមានការមានគ៌ភដោយបង្ខំ។ យោងតាមបណ្តាអ្នកស្រាវជ្រាវនានាបានឱ្យដឹងថា *"ពួកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យចង់ធ្វើឱ្យប្រាកដថា កុមារដែលកើតមកអាចបន្តវេនបដិវត្តន៍។ សម្រាប់ខ្មែរក្រហម គោលបំណងចម្បងនៃការរៀបអាពាហ៍ពិពាហ៍ ពុំមែនសំដៅបង្កើតក្រុមគ្រួសារឡើយ ប៉ុន្តែសំដៅបង្កើតកុមារដែលអាចនឹងបម្រើបដិវត្តន៍បាន"*[40]។ ជាលទ្ធផលនៃគោលនយោ

---

(ឆ) ការចាប់រំលោភ ទាសភាពផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគ៌ភដោយបង្ខំ ការធ្វើឱ្យគ្មានកូនដោយបង្ខំ ឬទម្រង់ផ្សេងណាមួយនៃអំពើហិង្សាផ្លូវភេទ ចំពោះស្ថានទម្ងន់ដែលអាចប្រៀបធៀបបាន [...]។ ។

[36] សូមមើលកថាខណ្ឌទី១៨។

[37] សូមមើលឯកសារយោងមុន២៦ ទំព័រ ២១៣។

[38] ការបញ្ជាក់ត្រូវបានដាក់បន្ថែម។

[39] ធាតុផ្សំនៃឧក្រិដ្ឋកម្មក្រោមច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧ (១) (ឆ)-៤។

[40] សូមមើលឌី ខាំបូលី ឯកសារយោងមុន៣ ទំព័រ៣៥។

បាយខ្មែរក្រហម ស្ត្រីមួយចំនួនត្រូវបានធ្វើឱ្យមានគ៌ភដោយបង្ខំ។ ស្ត្រីទាំងនោះត្រូវបន្តធ្វើការជាប្រក្រតីតាមវាលស្រែអំឡុងពេល និងក្រោយពេលមានគ៌ភ។ ចេតនារបស់អង្គការក្នុងការបង្ខំឱ្យមានការមានគ៌ភសំដៅបង្កើតឱ្យមាន "ក្រុមការងារប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើការងារសំដៅឆ្ពោះទៅ សម្រេចបានទិន្នផលមួយក្នុងកម្រិតជាអតិបរមា"[41] គឺជាការរំលោភមួយដ៏ធ្ងន់ធ្ងរទៅលើជនស៊ីវិលកម្ពុជា[42]។

ហេតុនេះ វាបានបំពេញគ្រប់សមាសធាតុផ្សំដែលចាំបាច់នៃ ឧក្រិដ្ឋកម្មដែលបានគូសបញ្ជាក់ស្តីពីការមានគ៌ភដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

## II. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថ្មី ក្រោមមាត្រា៥ នៃច្បាប់ អ.វ.ត.ក

២៨. ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តទាំងឡាយ ដែលចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ការចាប់រំលោភ ការដាក់ជាទាសករ ការមានគ៌ភដោយបង្ខំ) ពុំបានគ្របទៅលើស្ថានទម្ងន់ទោសទាំងមូលនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។

លើសពីនេះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានបំពេញសមាសធាតុផ្សំបន្ថែមដែលបង្កើតឱ្យបានប្រភេទផ្សេងមួយទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលស្ថិតក្រោមពាក្យថា "អំពើអមនុស្សធម៌ផ្សេងៗ" នៃមាត្រា៥ នៃច្បាប់អ.វ.ត.ក។

ដោយគិតទៅដល់សេចក្តីសម្រេចថ្មីៗ នៃតុលាការពិសេសសម្រាប់Sierra Leone ឃើញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានទទួលស្គាល់រួចហើយក្នុងកម្រិតអន្តរជាតិ[43]។ បើទោះបីយ៉ាងដូច្នេះក្តី ទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងបរិបទ

---

[41] សូមមើលឯកសារយោងមុន ៣០ ទំព័រ៥៩។

[42] យោងតាម Boon ចេតនានៃការអនុវត្តន៍ការរំលោភដ៏ធ្ងន់ធ្ងរផ្សេងៗទៅលើច្បាប់អន្តរជាតិ" ត្រូវយកមកអនុវត្តដោយមិនគិតពីពូជសាសន៍ វប្បធម៌ ឬសាសនា និងត្រូវនឹងសភាពការណ៍ជាញឹកញយ ដែលក្នុងនោះសមាជិកនៃកងទ័ព រំលោភបំពានជនស៊ីវិលរបស់ខ្លួន (សូមមើល Kristen Boon ការចាប់រំលោភ និង ការមានគ៌ភដោយបង្ខំ ក្រោមច្បាប់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្តីថ្លៃថ្នូររបស់មនុស្ស ស្វ័យភាព និងការព្រមព្រៀង Columbia Human Rights Law Review (២០០១) កថាខណ្ឌ៦២៥-៦៧៥ ទំព័រ៦៦៥។

[43] សូមមើលឯកសារយោងមុន១៦។

កម្ពុជា វាខុសប្លែកគ្នាពីករណីនៅSierra Leone ហើយហេតុដូច្នេះវាបង្ហាញវិធីសាស្ត្រដែលមានលក្ខណៈពិសេសតែមួយគត់មួយ។

២៩. ដូចក្នុងសំណុំរឿងនៅSierra Leone ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបង្ហាញថាជាសំខាន់វាជាអំពើហឹង្សាប្រព្រឹត្តដោយពួកឧទ្ទាមម្នាក់ៗប្រឆាំងនឹងស្ត្រី រីឯនៅកម្ពុជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានអនុវត្តដោយសារវាជារឿងមួយនៃគោលនយោបាយរដ្ឋ[44]។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានប្រើប្រាស់ជាមធ្យោបាយសំដៅធ្វើឱ្យរចនាសម្ព័ន្ធគ្រួសារចុះខ្សោយ និងដើម្បីធានាបានភក្តីភាពរបស់ប្រជាជនចំពោះរបបនោះ។ តាមរយៈការបង្ខំប្រជាជនឱ្យរៀបការដោយពុំបានព្រៀងទុក ខ្មែរក្រហមមានចេតនាចង់បានការគ្រប់គ្រងទៅលើជីវភាពផ្លូវភេទរបស់ប្រជាជន និងធ្វើឱ្យប្រាកដថាតួនាទីបន្តពូជត្រូវបានគ្រប់គ្រងចាត់ចែងដោយរដ្ឋ សំដៅផលិតពលករបន្ថែមទៀតសម្រាប់បដិវត្តន៍[45]។ ខ្មែរក្រហមបានអនុវត្តការដាក់កំណត់តឹងរឹង ទៅលើការជួបគ្នារវាងប្ដីប្រពន្ធ។ ទំនាក់ទំនងពួកគេស្ថិតក្រោមការឃ្លាំមើលជាអចិន្ត្រៃយ៍ពីសំណាក់"បក្ស"[46]។ ប្ដី ប្រពន្ធត្រូវបានបង្ខំឱ្យអនុវត្តការរួមភេទជាមួយគ្នាតាមបញ្ជាបក្ស និងត្រូវបង្កើតកូនចៅឱ្យបក្ស។ លើសពីការរំលោភបំពានដ៏ធ្ងន់ធ្ងរមួយទៅលើបូរណភាពផ្លូវភេទជនរងគ្រោះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅកម្ពុជាស្ដែងឱ្យឃើញថាជាការដកហូតស្ទើរទាំងស្រុងនូវស្វ័យភាព និងសិទ្ធិស្វ័យសម្រេច។

៣០. ធាតុផ្សំសំខាន់ៗ នៃឧក្រិដ្ឋកម្មស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ រួមមានដូចជា[47]៖

- ឧក្រិដ្ឋជនបានអនុញ្ញាតឱ្យមានស្ថានភាពនៃការរៀបអាពាហ៍ពិពាហ៍មួយតាមរយៈជាពាក្យសម្ដី ឬការអនុវត្តន៍កម្លាំង ឬការបង្ខិតបង្ខំ ដូចជាបង្កឡើងតាមរយៈការភ័យខ្លាចអំពើហឹង្សា ការចាប់គុក ការឃុំខ្លួន ការគាប

---

[44] សូមមើល Neha Jain ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាឧក្រិដ្ឋកម្មមួយប្រឆាំងនឹងមនុស្សជាតិ៖ បញ្ហានៃនិយមន័យ និងការប្រហារជីវិត ២០០៨ (ពុំទាន់បោះពុម្ពផ្សាយ) ទំព័រ១៤។

[45] សូមមើលឯកសារយោងមុន៤៤ ទំព័រ១៣។

[46] សូមមើលឯកសារយោងមុន៣០ ទំព័រ៥៩ និង៧០។

[47] កថាខណ្ឌទី១ និងទី២ យោងតាមNeha Jain សូមមើលឯកសារយោងមុន៤៤ ទំព័រ១៩។

សង្កត់ផ្លូវចិត្ត ឬការរំលោភអំណាចប្រឆាំងនឹងជនរងគ្រោះ ឬតាមរយៈការទាញយកផលចំណេញពីបរិស្ថានចាប់បង្ខំ ឬភាពអសមត្ថភាពរបស់ជននោះក្នុងការសម្តែងការព្រមព្រៀងដោយពិតប្រាកដ[48]។

- ឧក្រិដ្ឋជនបានបង្កឱ្យជនរងគ្រោះ ចូលរួមក្នុងការអនុវត្តន៍ទង្វើស្រដៀងទៅនឹងអំពើដែលកើតឡើងចេញពីសម្ព័ន្ធភាពអាពាហ៍ពិពាហ៍ រាប់ទាំងការសេពគប់រយៈពេលយូរអំពើនៃសារជាតិផ្លូវភេទការបង្កើតកូន និងការប្រគល់ឱ្យនូវភារកិច្ចជាប្តីប្រពន្ធផ្សេងៗ។
- ឧក្រិដ្ឋជន បានបង្កឱ្យមានការបាត់បង់ព្រហ្មចារីយ៍ និងបង្ខូចតម្លៃអាពាហ៍ពិពាហ៍ទៅឱ្យជនណាម្នាក់ដែលត្រូវបានគេជ្រើសរើសដោយសេរី និងហាមឃាត់ជននោះមិនឱ្យលែងលះគ្នា ព្រោះបានសន្យារួមរស់ជាមួយគ្នាជារៀងរហូត។

៣១. ជាទូទៅការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការអន្តរាគមន៍ដោយខុសច្បាប់មួយចូលទៅក្នុងបូរណភាពនៃបុគ្គលម្នាក់ ដែលវាបានបង្កឱ្យមានការរងទុក្ខវេទនាផ្លូវកាយ និងផ្លូវចិត្ត និងស្មើទៅនឹងការវាយប្រហារដ៏ធ្ងន់ធ្ងរមួយ ទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[49]។

៣២. ខណៈពេលនៅ Sierra Leoneជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះជាចម្បងគឺជាស្ត្រី នៅកម្ពុជា គូភាគីទាំងនោះត្រូវបានបង្ខំឱ្យរៀបការនឹងគ្នា។ ហេតុនេះក្រោមរបបខ្មែរក្រហមទាំងបុរស និងស្ត្រីសុទ្ធតែជាជនរងគ្រោះ នៃឧក្រិដ្ឋកម្មស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

---

[48] គេយល់ថា អ្វីដែលនៅសេសសល់ក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការផ្លាស់ប្តូររបស់វាទៅជាស្ថានការណ៍ដែលគ្រាន់តែព្រមព្រៀងគ្នា ពុំបានប៉ះពាល់ដល់អំពើឧក្រិដ្ឋកម្មដើមឡើយ។

[49] រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzindana (សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា-៩៥-១-T) អង្គជំនុំជម្រះ ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ សាលក្រម កថាខណ្ឌ១៤៩-១៥១ រដ្ឋអាជ្ញា ទល់នឹង Bagilishema (សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា-៩៥-១-T) អង្គជំនុំជម្រះ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ សាលក្រមកថាខណ្ឌទី៩១-៩២។

## III. ឧក្រិដ្ឋកម្មស្ទួន

នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានសម្រេចថា គេអាចមានលទ្ធភាពចោទនូវបទល្មើសផ្លូវច្បាប់ខុសៗគ្នា ទាក់ទងនឹងអង្គហេតុតែមួយ[50]។ នៅលើមូលដ្ឋានច្បាប់ (ជាពិសេស ច្បាប់បារាំង) និងច្បាប់អន្តរជាតិ និងយុត្តិសាស្ត្រ សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់អះអាងជាថ្មីថា គេអាចទទួលយកបានក្នុងការចោទប្រកាន់ជនត្រូវចោទនូវបទល្មើសមួយចំនួន ដែលទាក់ទងនឹងបណ្តុំអង្គហេតុតែមួយនៅពេលណាបទល្មើសមានសមាសធាតុផ្សំខុសៗគ្នា និងការពារផលប្រយោជន៍ខុសៗគ្នា[51]។

---

[50] សំណុំរឿងកាំង ហ្កេកអ៊ាវ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/ក.ស.ច.ស សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្ថាពរ ដែលបញ្ជូនឈ្មោះកាំង ហ្កេកអ៊ាវ ហៅឌុច ទៅជំនុំជម្រះ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ D99/3/42 កថាខណ្ឌទី៨៦ ff: អង្គបុរេជំនុំជម្រះ បានបញ្ជាក់ថា “ទាំងវិធានផ្ទៃក្នុង និងច្បាប់កម្ពុជា សុទ្ធតែគ្មានចែងបទប្បញ្ញត្តិទាក់ទិននឹងលទ្ធភាពនៃការកំណត់បទល្មើសផ្លូវច្បាប់ផ្សេងៗ សម្រាប់អំពើតែមួយ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូចបានបញ្ជាក់ក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង អង្គបុរេជំនុំជម្រះនឹងស្វែងរកការណែនាំក្នុងវិធាននីតិវិធី ដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ យុត្តិសាស្ត្រនៃសាលាក្តីអន្តរជាតិពិសេស ចែងថាគេអាចអនុញ្ញាតបាន ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ក្នុងការរាប់បញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នូវបទល្មើសផ្លូវច្បាប់ខុសៗគ្នា ដែលទាក់ទិននឹងអំពើតែមួយ។ ទាំងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងរ៉្វាន់ដា មានយុត្តិសាស្ត្រដ៏សន្ធឹកសន្ធាប់ គាំទ្រដល់ការប្រើប្រាស់ការចោទប្រកាន់ផ្ទួនៗគ្នា។ តុលាការពិសេសសម្រាប់Sierra Leoneក៏បានគាំទ្រការអនុវត្តន៍នេះដែរ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញទៀតថា ការបញ្ចូលបទល្មើសផ្លូវច្បាប់លើសពីមួយទាក់ទិននឹងអំពើតែមួយទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំមែនជាការគម្រាមកំហែងជាមូលដ្ឋានដល់គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទឧក្រិដ្ឋតែមួយ (ne bis in idem) ឡើយ ព្រោះវាពុំបានជាប់ទាក់ទងក្នុងការចាត់តាំងការទទួលខុសត្រូវពិតប្រាកដ ឬការដាក់ទណ្ឌ កម្ម”។

[51] សូមមើលរដ្ឋអាជ្ញា ទល់នឹង Akayesu (សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា-៩៦-៤-T) អង្គជំនុំជម្រះ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ សាលក្រម កថាខណ្ឌទី៤៦៨ រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzindana (សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា-៩៥-១-T) អង្គជំនុំជម្រះ ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ សាលក្រម កថាខណ្ឌ៦២៧។ ដោយសារសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា បានអនុម័តយកវិធីសាស្ត្រដែលបានទទួលឥទ្ធិពលពីបារាំងនេះ វាហាក់បីដូចជាវិធីសាស្ត្រមួយដែលត្រូវយកមកអនុវត្ត ក្នុងប្រព័ន្ធច្បាប់កម្ពុជា។ គោលការណ៍ច្បាប់បារាំង ដែលហៅថា “concours d'Infractions” មានការអនុវត្តន៍២ ប្រភេទពេលតុលាការ ពុំអាចរក ឃើញទោសជនត្រូវចោទលើសពីមួយ៖ “ទីមួយ ពេលបណ្តុំអង្គហេតុតែមួយ បណ្តាលឲ្យមានការដាក់ពាក្យសុំស្តីពីការផ្តល់ឲ្យនូវឧក្រិដ្ឋកម្មចម្រុះ និងទីពីរ (concours ideal d'Infraction) ពេលអង្គហេតុអាច ស្ថិតនៅក្រោមការផ្តល់ឲ្យ ចម្រុះ

៣៤. ឧក្រិដ្ឋកម្មស្តីពីការចាប់រំលោភ ការដាក់ជាទាសករ ការមានគ៌ភដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានស្ថានទម្ងន់ទោសតាមច្បាប់ខុសៗគ្នា និងអាចត្រូវបានចោទប្រកាន់បន្ថែមផ្ទួនៗពីលើគ្នា។ ផលប្រយោជន៍នៃការចាប់រំលោភដែលត្រូវបានការពារដោយច្បាប់គឺជាស្វ័យសម្រេចរបស់បុគ្គលម្នាក់។ ឧក្រិដ្ឋកម្មស្តីពីការមានគ៌ភដោយបង្ខំដែលត្រូវបានប្រព្រឹត្តចំពោះតែស្ត្រីប៉ុណ្ណោះគឺជាអន្តរាយ ដែលផ្សេងពីការចាប់រំលោភ និងផ្សេងពីទម្រង់ផ្សេងទៀតនៃការបៀតបៀនផ្លូវភេទ ការធ្វើឱ្យមានគ៌ភដោយបង្ខំ និងការបង្ខាំងស្ត្រីភេទ។ ការមានគ៌ភដោយបង្ខំ ពាក់ព័ន្ធនឹងសេរីភាពបន្តពូជ និងស្វ័យភាពផ្លូវភេទ[52]។ ការមានគ៌ភដោយពុំបានព្រាងទុក និងដោយពុំចង់មានផលវិបាកបន្ថែម និងរយៈពេលយូរទៅដល់ភាពជាម្តាយ ទំនួលខុសត្រូវហិរញ្ញវត្ថុ និងការលំបាកផ្នែកសុខភាពដែលនឹងអាចកើតមាន[53]។

ការដាក់ជាទាសកររួមបញ្ចូលផលប្រយោជន៍នៃការផ្លាស់ទីដោយសេរី ដោយគ្មានការគ្រប់គ្រងពីសំណាក់តតិយបុគ្គល។

សមាសធាតុផ្សំសំខាន់ៗនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺខុសផ្សេងពីឧក្រិដ្ឋកម្មឯទៀត និងពុំសូវផ្តោតទៅលើផ្នែកផ្លូវភេទ ក៏ប៉ុន្តែវាផ្តោតច្រើនទៅលើការកេណ្ឌមនុស្សឱ្យចូលទៅក្នុងសម្ព័ន្ធភាពប្តីប្រពន្ធ ព្រមទាំងការបាត់បង់ព្រហ្មចារីយ៍ និងការពុំរាប់បញ្ចូលការលែងលះគ្នា និងការរៀបអាពាហ៍ពិពាហ៍ឡើងវិញ។ លើសពីនេះ ឋានៈនិងកេរ្តិ៍ឈ្មោះក្នុងសង្គម របស់ជនរងគ្រោះស្ត្រី ត្រូវបាននៅដូច្នេះជារៀងរហូត ក៏ដោយសារតែត្រូវបានសង្គមចាត់ទុកថាជាមនុស្សរៀបការរួច។

## IV. សញ្ញាណនៃការព្រមព្រៀងក្នុងក្របខណ្ឌច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

---

ដែលខុសគ្នាដោយសារជាតិ ប៉ុន្តែត្រូវបានសម្គាល់ទៅលើធាតុផ្សំ ភស្តុតាងតែមួយ" សូមមើល Attila Bogdan ការចោទប្រកាន់ផ្ទួនៗគ្នា ការផ្តន្ទាទោស និងការកាត់ទោស នៅឯសាលាក្តីអន្តរជាតិពិសេស សម្រាប់អតីតយូហ្គោស្លាវី និងរ្វ៉ាន់ដា Melbourne Journal of International Law ២០០២ http://www.austlii.edu.au /au/journals /MelbJIL/2002/1.html ដែលបានចូលអានកាលពីថ្ងៃ ទី២៧ ខែមករា ឆ្នាំ២០០៩ ទំព័រទី៦ និងទី៧។

[52] សូមមើលឯកសារយោងមុខ៤២ ទំព័រ៦៥៥។

[53] សូមមើលឯកសារយោងមុខ៤២ ទំព័រ៦៥៨។

៣៥. ជាឧក្រិដ្ឋកម្មអន្តរជាតិ អំពើហឹង្សាផ្លូវភេទ ដែលជាផ្នែកមួយនៃការវាយប្រហារមួយដែលមានលក្ខណៈរីករាលដាល ឬជាប្រព័ន្ធ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) ឬត្រូវបានធ្វើឡើងសំដៅប្រឆាំងនឹងក្រុមមួយដែលត្រូវបានគេការពារ(ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍) ឬត្រូវបានប្រព្រឹត្តក្នុងក្របខ័ណ្ឌជម្លោះប្រដាប់អាវុធមួយ គឺលើសពីអំពើតែមួយប្រឆាំងនឹងបុគ្គលម្នាក់។

ដូចនេះ បទដ្ឋាននៃការយល់ព្រម ដូចជាក្នុងករណីច្បាប់ជាតិ ត្រូវតែមានបញ្ចូលបទឧក្រិដ្ឋអន្តរជាតិ និងកាលៈទេសៈនៃបទឧក្រិដ្ឋនោះ ដែលមានលក្ខណៈខុសពីបទឧក្រិដ្ឋជាតិ។ បើទោះបីជាភស្តុតាងបញ្ជាក់អំពីការពុំព្រមព្រៀងមិនត្រូវបានតម្រូវឱ្យមានជាចាំបាច់សម្រាប់ឧក្រិដ្ឋកម្មផ្សេងៗដូចជា ការធ្វើទារុណកម្ម ការប្រហារជីវិត ឬការដាក់ជាទាសករក្តី ក៏វាគ្មានភាពសមហេតុផលក្នុងការតម្រូវឱ្យមានធាតុផ្សំនេះសម្រាប់ឧក្រិដ្ឋកម្មផ្លូវភេទ[54]។

៣៦. ដោយត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មមួយប្រឆាំងនឹងមនុស្សជាតិ អំពើតែមួយក៏អាចបង្កើតដោយពិតប្រាកដ ជាផ្នែកមួយនៃការវាយប្រហារដែលមានលក្ខណៈរីករាលដាល ឬជាប្រព័ន្ធ ហើយឧក្រិដ្ឋជនត្រូវដឹងថា ពលរដ្ឋគឺស្ថិតនៅក្រោមការវាយប្រហារ និងអំពើនោះជាផ្នែកមួយនៃការវាយប្រហារ។
ការវាយប្រហារដែលមានលក្ខណៈរីករាលដាល និងជាប្រព័ន្ធទៅលើពលរដ្ឋស៊ីវិលបែបនេះបង្កើតឱ្យមានកាលៈទេសៈចាប់បង្ខំកម្រិតខ្ពស់ ដែលបដិសេធចោលនូវលទ្ធភាពនៃការព្រមព្រៀងដោយពិតប្រាកដ[55]។

[54] Wolfgang dchomburg and Ines Peterson ការព្រមព្រៀងពិតប្រាកដ ចំពោះអំពើហឹង្សាផ្លូវភេទក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ 101 American Journal of International Law (២០០៧) ទំព័រ១២១ និង ១២៦។

[55] សូមមើលឯកសារយោងមុន៥៤ ទំព័រ១៣០ លើសពីនេះ អ្នកនិពន្ធបានស្នើឱ្យពិចារណាអំពីអំពើផ្លូវភេទរវាងបុគ្គលទាំងឡាយ ដែលគ្មានអំណាចស្មើគ្នា ដោយពុំគិតពីការព្រមព្រៀងរបស់ជនរងគ្រោះ។ វិធីសាស្ត្រនេះនឹងនាំឆ្ពោះទៅរកនិយាមនៃការទទួលខុសត្រូវដ៏តឹងរ៉ឹងមួយ ដែលមិនត្រឹមតែដកការពុំព្រមព្រៀងចេញពីធាតុផ្សំ នៃឧក្រិដ្ឋកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាគោលការណ៍ បដិសេធចោលនូវលទ្ធភាពនៃការលើកអំណះអំណាងថា ការព្រមព្រៀងជាការ ការពារខ្លួន ទំព័រទី១៣៨ ទី១៣៩។

៣៧. ការព្រមព្រៀងត្រូវតែសេរី យុត្តិធម៌ និងមានគុណប្រយោជន៍ដើម្បីឱ្យមានសុពលភាពផ្នែកសីលធម៌។ ពេលណាការព្រមព្រៀងត្រូវបានទទួលក្រោមកាលៈទេសៈនៃការចាប់បង្ខំពេលនោះការព្រមព្រៀងនោះគឺគ្មានសុពលភាព និងមិនត្រូវបានគេទទួលស្គាល់ទេ[56]។

៣៨. កាលៈទេសៈទាំងឡាយ ក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលការរៀបអាពាហ៍ពិពាហ៍ជាក្រុមត្រូវបានរៀបចំឡើង ជាទូទៅមានលក្ខណៈចាប់បង្ខំ។ ប្រសិនបើមិនធ្វើតាមបញ្ជានឹងឈានទៅដល់ការដាក់ទណ្ឌកម្ម ការយកទៅរៀនសូត្រ និងការស្លាប់។
ក្រោមកាលៈទេសៈបែបនេះការព្រមព្រៀងដោយស្ម័គ្រចិត្ត និងដោយពិតប្រាកដទៅលើការរៀបអាពាហ៍ពិពាហ៍ ស្ថានភាពគ្រួសារដែលពាក់ព័ន្ធ ការរួមភេទតាមបញ្ជា និងសម្ព័ន្ធភាពប្តីប្រពន្ធ គឺពុំមានលទ្ធភាពទៅរួចឡើយ[57]។

## ច. ភាពចាំបាច់នៃកិច្ចស៊ើបសួរបន្ថែម

៣៩. ចាប់តាំងពីយ៉ាងហោចណាស់ ក៏ក្នុងដើមឆ្នាំ១៩៧៧ដែរ ដែលការរៀបអាពាហ៍ពិពាហ៍ និងការបញ្ជាឱ្យប្តីប្រពន្ធរួមភេទ ត្រូវបានធ្វើ និងរៀបចំឡើងដោយមេដឹកនាំជាន់ខ្ពស់នៅទូទាំងប្រទេស[58]។ បើទោះបីជាគ្មានការបញ្ជាជាលាយលក្ខណ៍អក្សរពីគណៈកម្មាធិការអចិន្ត្រៃយ៍ក្តី វាច្បាស់ជាត្រូវបានគេសន្និដ្ឋាន ពីការអនុវត្តន៍ដូច្នេះនៅគ្រប់ទិសទីក្នុងប្រទេសថាបញ្ជានេះពិតជាមានមែន។
ដូចបានបង្ហាញប្រាប់ពីខាងដើម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ច្បាស់ណាស់ថា ត្រូវបានអនុវត្តជាបញ្ជាមួយនៃគោលនយោបាយរដ្ឋ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានប្រើប្រាស់ទូទាំងកម្ពុជា ជាវិធានការណ៍មួយសំដៅវាយប្រហារ និងធ្វើឱ្យគ្រួសារកម្ពុជាចុះអន់ខ្សោយ សំដៅបង្កើតកុមារច្រើនថែមទៀតសម្រាប់បម្រើបដិវត្តន៍ "អង្គការ" និងគ្រប់គ្រងអំណាចខាងផ្លូវភេទ និងបន្តពូជ។

---

[56] សូមមើលឯកសារយោងមុន៤២ ទំព័រទី៦៧២។

[57] សូមមើល Gacumbitsi ទល់នឹងរដ្ឋអាជ្ញា (សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា-២០០១-៦៤-A) សាលាឧទ្ធរណ៍សាលក្រម កថាខណ្ឌ១៥៥ ដែលសាលាឧទ្ធរណ៍នេះបានបញ្ជាក់ថា ការពុំព្រមព្រៀង អាចត្រូវ បានបង្ហាញតាមរយៈការបង្ហាញនូវអត្ថិភាព នៃកាលៈទេសៈចាប់បង្ខំ។

[58] សូមមើលឯកសារយោងមុន៣។

ហេតុដូច្នេះឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ជាផ្នែកមួយនៃការវាយប្រហារដែលមានលក្ខណៈរីករាលដាល និងជាប្រព័ន្ធសំដៅប្រឆាំងពលរដ្ឋស៊ីវិល។

៤០. ភស្តុតាងបង្ហាញថា យ៉ាងតិចណាស់ក៏មានការរៀបអាពាហ៍ពិពាហ៍មួយជាក្រុមដែរ បានកើតឡើងក្នុងចំណោមកម្មាភិបាល និងពេទ្យនៅឯ[បានលុបចោល][59] [បានលុបចោល] ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនត្រូវចោទផ្ទាល់ក្នុងតួនាទីជាប្រធាន។ គាត់បានសារភាពទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីនោះ[60]។ គាត់បានបញ្ជាឱ្យមានការរៀបចំអាពាហ៍ពិពាហ៍ជាក្រុមនៅ[បានលុបចោល] និងបានដឹងអំពីលក្ខណៈចាប់បង្ខំរបស់ពួកគេ។ ហេតុនេះគេមានហេតុផលគួរឱ្យជឿថា ជនត្រូវចោទបានដឹងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅគ្រប់ទិសទីក្នុងប្រទេស ថាជាការវាយប្រហារមួយប្រឆាំង នឹងពលរដ្ឋស៊ីវិល និងបានដឹងថាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅ[បានលុបចោល] ជាផ្នែកមួយនៃការវាយប្រហារដ៏រីករាលដាលនេះ។

៤១. កិច្ចស៊ើបសួរពុំទាន់បានផ្តោតទៅលើឧក្រិដ្ឋកម្មផ្លូវភេទឡើយ ឧទាហរណ៍ដូចជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បើទោះបីជាមានភស្តុតាងនៅក្នុងសំណុំរឿងដើម្បីចាប់ផ្តើមអនុវត្តកិច្ចស៊ើបសួរបន្ថែម និងដើម្បីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមក្តី។

៤២. McGrew[61] បានប៉ាន់ស្មានថា មានមនុស្សប្រុសស្រី ប្រមាណ៤សែននាក់ ដែលបានរៀបការនៅក្រោមរបបខ្មែរក្រហម ក្រោមកាលៈទេសៈដូចដែលបានបញ្ជាក់ខាងលើ[62]។

---

[59] សូមមើលឯកសារយោងមុខ៤។

[60] សំណុំរឿងកាំង ហ្គេកអ៊ាវ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/ក.ស.ច.ស ការស្តាប់ចម្លើយ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារលេខ D៣០ ការស្តាប់យកចម្លើយ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ ឯកសារលេខ D៦៣ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ឯកសារលេខ D១៣។

[61] សូមមើលឯកសារយោងមុខ១ សូមមើលផងដែរ Peg Le Vine (ឯកសារយោងមុខ៥) ដែលបានរាប់ក្នុងការស្រាវជ្រាវរបស់នាង ឃើញមានប្តីប្រពន្ធប្រមាណ១៧២០គូ ខណៈពេលប្រមូលសាច់រឿងអំពីដៃគូដែលត្រូវបានសម្ភាសទី១៩២របស់នាង។ ហេតុនេះយ៉ាងហោចណាស់ក៏មានមនុស្សទាក់ទងនឹងបញ្ហានេះចំនួន ៣៤៤០ នាក់ដែរ។

ដោយពិចារណាដល់វិសាលភាពនៃឧក្រិដ្ឋកម្មដែលមានលក្ខណៈរីករាលនេះ សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើការិយាល័យសហព្រះរាជអាជ្ញាមេត្តាអនុវត្តកិច្ចស៊ើបសួរថ្មី និងបញ្ចូលឧក្រិដ្ឋកម្មស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ទៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដោយសេចក្តីអនុគ្រោះ។

៤៣. ដើម្បីបំពេញអាណត្តិ អ.វ.ត.ក ដើម្បីបញ្ជាក់អះអាងការពិត (ទាំងស្រុង) និងដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះដូចជាការចាប់រំលោភ ការដាក់ជាទាសករ ការមានគ៌ភដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មថ្មី ត្រូវតែត្រូវបានគេដាក់បញ្ចូលក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ បើយើងគិតអំពីចំនួនដ៏ច្រើននៃជនរងគ្រោះ និងផលប៉ះពាល់ជាអវិជ្ជមានរបស់វាទៅលើសង្គមកម្ពុជា ឃើញថាវាមានយុត្តិកម្ម និងលើសពីចាំបាច់ទៅទៀតក្នុងការចាប់ផ្តើមអនុវត្តកិច្ចស៊ើបសួរ។

៤៤. កិច្ចស៊ើបសួរដែលចាំបាច់ គួរក្តោបយកការស្តាប់ចម្លើយសាក្សីនៅ[បានលុបចោល]ស្តីពីកាលៈទេសៈនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយកិច្ចស៊ើបសួរគួរតែធ្វើបន្ទាប់ពីនោះប្រសិនបើអាចកំណត់អត្តសញ្ញាណជនរងគ្រោះបាន។
ប្រសិនបើសាក្សីត្រូវបានស្តាប់យកចម្លើយដោយរហ័ស ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក៏អាចសម្រេចដោយរហ័សដែរ ហើយអាចនឹងត្រូវបានបញ្ជូនទៅការិយាល័យចៅក្រមស៊ើបអង្កេតដើម្បីធ្វើដីកាស្តាពរបន្ថែម។
ហេតុដូច្នេះគេមានលទ្ធភាពក្នុងការបន្ថែមបទចោទថ្មីៗ ដើម្បីឲ្យជនត្រូវចោទទទួលខុសត្រូវចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅ[បានលុបចោល]។

៤៥ និយាយអំពីការវិវត្តក្នុងសាលាក្តីអន្តរជាតិ និងអន្តរជាតូបនីយកម្មផ្សេងៗចំពោះការបញ្ចូលឧក្រិដ្ឋកម្មទាក់ទិននឹងភេទក្នុងយុត្តាធិការរបស់ខ្លួន អ.វ.ត.ក គួរយកគម្រូតាមតុលាការផ្សេងៗ និងទទួលស្គាល់ទំហំនៃឧក្រិដ្ឋកម្មទាំងនោះ ក៏ដូចជាផលប៉ះពាល់ទៅលើសង្គម។

---

[62] សូមមើលឯកសារយោងមុខ៣ និង៥។

ការិយាល័យសហព្រះរាជអាជ្ញាមិនគួរមានបញ្ហាទាក់ទងនឹងឆន្ទានុសិទ្ធិ ទាក់ទិននឹងការអនុវត្តន៍មានលក្ខណៈរីករាលដាលនេះ ក្នុងអំឡុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ និងទំហំនៃកិច្ចស៊ើបសួរដែលអាចចាត់ចែងបាននោះទេ។

ហេតុដូច្នេះ

សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើមន្ត្រី នៃការិយាល័យសហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៤៩ នៃវិធានផ្ទៃក្នុង

មេត្តាអនុវត្តកិច្ចស៊ើបសួរបន្ថែម ទៅលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅឯ[ប្រានលុបចោល]មេត្តាដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទៅលើមូលដ្ឋាននៃភស្តុតាងដែលត្រូវបានលើកយកមកបង្ហាញ។

| | |
|---|---|
| ហុង គីមសួន<br>សហមេធាវីមកពីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា | យ៉ុង ផានិត<br>សហមេធាវីមកពីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| គង់ ពិសី<br>សហមេធាវីមកពីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា | Silke Studzinsky<br>សហមេធាវី |
| គីម ម៉េងឃី<br>សហមេធាវីមកពីក្រុមមេធាវីគ្មានព្រំដែន | ម៉ុច សុវណ្ណារី<br>សហមេធាវីមកពីក្រុមមេធាវីគ្មានព្រំដែន |

ចុះហត្ថលេខា នៅភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៩។